


# AIA 100 ការពារ

## បង្កើនការការពារជំងឺធ្ងន់ធ្ងរជាមួយការរៀបចំផែនការឆ្ពោះទៅមុខ

មនុស្សប្រមាណជាង 41 លាននាក់បានស្លាប់ដោយសារជំងឺមិនឆ្លង ដែលក្នុងនោះ 74% នៃការស្លាប់ទាំងអស់នៅទូទាំងពិភពលោកបង្កពីជំងឺសរសៃឈាមបេះដូង (ជំងឺបេះដូង និងដាច់សរសៃឈាមខួរក្បាល) មហារីក ជំងឺទឹកនោមផ្អែម និងជំងឺសួតរ៉ាំរ៉ៃ។ អង្គការសុខភាពពិភពលោក (WHO) បាននិយាយថា 67.7% នៃការស្លាប់នៅក្នុងប្រទេសកម្ពុជា បណ្តាលមកពីជំងឺ NCDs ក្នុងឆ្នាំ 2019។

**AIA 100 ការពារ** បង្កើតឡើងជាពិសេសក្នុងការជួយបង្កើនការការពារលើជំងឺធ្ងន់ធ្ងរ ដែលជាជម្រើសដ៏សក្តិសមសម្រាប់អ្នកដែលចង់បានគម្រោងដែលផ្តល់ការគិតគូរដ៏វែងឆ្ងាយមួយ។ លោកអ្នកអាចធានាបានថា ការចំណាយផ្ទាល់ខ្លួនលើការព្យាបាលយ៉ាងតិចបំផុត ជាមួយនឹងដំណោះស្រាយដែលថែទាំអ្នកពីការធ្វើរោគវិនិច្ឆ័យរហូតដល់ការជាសះស្បើយឡើងវិញ។

## ហេតុអ្វី AIA 100 ការពារ ជាជម្រើសដ៏សំខាន់សម្រាប់លោកអ្នក?

ដំបូងគេនៅក្នុងទីផ្សារផ្តល់ការការពាររហូតដល់ 118 ករណីនៃជំងឺធ្ងន់ធ្ងរ ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ

ផ្តល់សំណងរហូតដល់ 50% នៃអត្ថប្រយោជន៍សរុប នៅពេលធ្វើរោគវិនិច្ឆ័យនៃជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង

បន្ថែមការការពារលើជំងឺ និងករណីបណ្តាលមកពីផលវិបាកនៃជំងឺទឹកនោមផ្អែម

ផ្តល់ការការពារបន្ថែមសម្រាប់កុមារ លើករណីនៃជំងឺធ្ងន់ធ្ងរចាប់ពីអាយុ 30 ថ្ងៃ

សេវាគ្រប់គ្រង និងការប្រឹក្សាព្យាបាលផ្ទាល់ខ្លួន (PMCM) ការពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួន និងការណែនាំអំពីមតិទីពីរពីអ្នកជំនាញនៅក្រៅប្រទេស*

**សេវាកម្មនេះមិនរាប់បញ្ចូលថ្លៃធ្វើដំណើរ និងថ្លៃព្យាបាលទេ។*

## អត្ថប្រយោជន៍ពិសេសសំខាន់ៗ

**ការការពារ និងអត្ថប្រយោជន៍ទទួលបានមានដូចបង្ហាញខាងក្រោម៖**

| ប្រភេទនៃការធានា | អត្ថប្រយោជន៍ផ្តល់ជូន |
|---|---|
| អត្ថប្រយោជន៍ផលវិបាកនៃជំងឺទឹកនោមផ្អែម | រហូតដល់ 20% នៃទឹកប្រាក់ធានារ៉ាប់រង |
| អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | រហូតដល់ 50% នៃទឹកប្រាក់ធានារ៉ាប់រង |
| អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ | រហូតដល់ 100% នៃទឹកប្រាក់ធានារ៉ាប់រង |

ការទូទាត់សរុបដែលបានធ្វើឡើងសម្រាប់អត្ថប្រយោជន៍ផលវិបាកនៃជំងឺទឹកនោមផ្អែម អត្ថប្រយោជន៍ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង និងអត្ថប្រយោជន៍ដំណាក់កាលចុងក្រោយ គឺមិនលើសពី100%នៃទឹកប្រាក់ធានារ៉ាប់រងសម្រាប់ផលិតផល **AIA 100 ការពារ**។ អត្ថប្រយោជន៍ការពារគ្រួសារ (អត្ថប្រយោជន៍លើមរណភាព) នឹងត្រូវកាត់បន្ថយលើទំហំនៃទឹកប្រាក់ធានារ៉ាប់រង នៅពេលផលិតផលធានារ៉ាប់រងបន្ថែមនេះត្រូវបានផ្តល់សំណងរួចរាល់។

## លក្ខខណ្ឌដែលអាចទទួលបានការធានា

- អាយុ 30 ថ្ងៃ - 60 ឆ្នាំ
- ទទួលយកការការពារពី អេ អាយ អេ លើផលិតផលធានារ៉ាប់រងមូលដ្ឋានណាមួយដែលអនុញ្ញាតអោយភ្ជាប់ជាមួយផលិតផលធានារ៉ាប់រងបន្ថែមនេះ។

## តារាងប្រភេទជំងឺបណ្តាលពីផលវិបាកនៃជំងឺទឹកនោមផ្អែមសម្រាប់អ្នកត្រូវបានធានារ៉ាប់រងអាយុ 18 - 70 ឆ្នាំ

| ប្រភេទជំងឺធ្ងន់ធ្ងរ | ផលវិបាកនៃជំងឺទឹកនោមផ្អែម |
|---|---|
| **ជំងឺទឹកនោមផ្អែម** | 1. ការកាត់ដៃ ឬជើងចេញដោយសារដោយសារតែផលវិបាកនៃជំងឺទឹកនោមផ្អែម<br>2. ការរលាកបាតភ្នែកដោយសារផលវិបាកនៃជំងឺទឹកនោមផ្អែម<br>3. ការខូចតម្រងនោមដោយសារផលវិបាកនៃជំងឺទឹកនោមផ្អែម |

# តារាងប្រភេទជំងឺធ្ងន់ធ្ងរសម្រាប់អ្នកត្រូវបានធានារ៉ាប់រងអាយុ 30 ថ្ងៃ - 70 ឆ្នាំ

| ប្រភេទជំងឺធ្ងន់ធ្ងរ | ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ |
|---|---|---|
| **ជំងឺខួរក្បាល** | 1. ការដាក់បំពង់បង្ហូរសារធាតុរាវចេញពីខួរក្បាល (ឧបករណ៍ Shunt)<br>2. ការវះកាត់ដុំសាច់Pituitaryជាផ្នែកមួយក្នុងខួរក្បាល<br>3. ជំងឺរលាកស្រោមខួរបង្កដោយបាក់តេរី ដែលអាចជាសះស្បើយពេញលេញ<br>4. ជំងឺវិបត្តប្រព័ន្ធប្រសាទចលនា ផ្នែកខាងជាយ (Peripheral Motor Neuropathy)<br>5. ជំងឺប៉ាគីនសុន (Parkinson's Disease) កម្រិតស្រាល<br>6. ការវះកាត់ នៃការរីកប៉ោងនៃសរសៃឈាមខួរក្បាល<br>7. ការសន្លប់បាត់បង់ស្មារតី អស់រយៈពេល 72ម៉ោង<br>8. ជំងឺរលាកខួរក្បាលកម្រិតមធ្យម<br>9. មនុស្សរុក្ខជាតិ<br>10. ជំងឺឆ្កួតជ្រូកកម្រិតធ្ងន់ធ្ងរ | 25. ជំងឺរលាកខួរក្បាលបង្កដោយបាក់តេរី ដែលខូចសរសៃប្រសាទជាអចិន្ត្រៃយ៍<br>26. ជំងឺរលាកខួរក្បាល ដែលខូចសរសៃប្រសាទជាអចិន្ត្រៃយ៍<br>27. សន្លប់ - បណ្ដាលឱ្យមានឱនភាពនៃសរសៃប្រសាអចិន្ត្រៃយ៍ជាមួយនឹងរោគសញ្ញាគ្លីនិក<br>28. ការវះកាត់ដុំសាច់ខួរក្បាល ដោយមានភាពធ្ងន់ធ្ងរជាក់លាក់<br>29. ការវះកាត់ខួរក្បាល<br>30. ជំងឺភ្លេចភ្លាំង/ជំងឺវង្វេងធ្ងន់ធ្ងរ<br>31. Persistent Vegetative State (រោគសញ្ញា Apallic)<br>32. ការដាច់សរសៃឈាមខួរក្បាលដែលទាមទារការវះកាត់ខួរក្បាល<br>33. ជំងឺមិនអាចនិយាយរួចដែលមិនអាចត្រលប់មកធម្មតាបាន<br>34. ជំងឺបំផ្លាញកោសិកាសរសៃប្រសាទ<br>35. ជំងឺផាគីនសុន<br>36. ការវះកាត់ការរៀចឆ្អឹងខ្នង<br>37. ការបាត់បង់ការគ្រប់គ្រងខ្លួនឯង<br>38. ការវិវឌ្ឍនៃពិការភាព Supranuclear |
| **ជំងឺមហារីក** | 11. ជាលិកាមហារីកកកើតនៅទីតាំងដើម (CIS)<br>12. មហារីកក្រពេញប្រូស្តាតដំណាក់កាលដំបូង<br>13. មហារីកក្រពេញទីរ៉ូអ៊ីតដំណាក់កាលដំបូង<br>14. មហារីកប្លោកនោមដំណាក់កាលដំបូង<br>15. មហារីកគ្រាប់ឈាម ស រ៉ាំរ៉ៃដំណាក់កាលដំបូង<br>16. ជំងឺមហារីកជញ្ជាំងផ្នែកខាងក្នុង ក្រពះពោះវៀន<br>17. ជំងឺមហារីកកោសិកាស្បែកមេឡាណូស៊ីត ដំណាក់កាលដំបូង (Early Melanoma) | 39. ជំងឺមហារីក - កម្រិតធ្ងន់ធ្ងរដោយមិនរាប់បញ្ចូលជំងឺមហារីកដំណាក់កាលដំបូង |
| **ជំងឺក្រពះពោះវៀន** | 18. ជំងឺក្រិនប្រមាត់<br>19. ការស្លាប់ជាលិកាលំពែងស្រួចស្រាវ<br>20. ការវិឌ្ឍន៍នៃជំងឺក្រិនស្បែក ជាមួយជំងឺក្រេស | 40. ជំងឺរលាកលំពែងរ៉ាំរ៉ៃដែលលាប់មកឡើងវិញ<br>41. ជំងឺប្រពន្ធ័រំលាយអាហារក្រូនដែលបង្កអោយមានបុសអន្ទង់<br>42. ការវះកាត់ផ្នែកទាំងមូលនៃពោះវៀនតូច |
| **ជំងឺថ្លើម** | 21. ការវះកាត់យកថ្លើមយ៉ាងតិចមួយខ្លែបចេញ (ក្នុងចំណោមប្រាំបីខ្លែប)<br>22. ជំងឺក្រិនថ្លើមដែលបង្ករដោយមេរោគ | 43. ការខូចថ្លើមដំណាក់កាលចុងក្រោយ<br>44. រលាកថ្លើមដោយមេរោគ<br>45. រលាកថ្លើមរ៉ាំរ៉ៃ |
| **ជំងឺសួត** | 23. ជំងឺរបេង<br>24. ការវះកាត់យកសួតមួយចេញ (ក្នុងចំណោមសួតពីរ) | 46. ជំងឺសួតដំណាក់កាលចុងក្រោយ<br>47. ជំងឺក្រិនសួតធ្ងន់ធ្ងរ |

# តារាងប្រភេទជំងឺធ្ងន់ធ្ងរសម្រាប់អ្នកត្រូវបានធានារ៉ាប់រងអាយុ 30 ថ្ងៃ - 70 ឆ្នាំ

| ប្រភេទជំងឺធ្ងន់ធ្ងរ | ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ |
|---|---|---|
| **ជំងឺបេះដូង និងប្រព័ន្ធសរសៃឈាម** | 48. ចង្កោមរោគសញ្ញានៃជំងឺវិបត្តការវិវត្តពេញវ័យ នៃកោសិកាគ្រាប់ឈាមក្រហមក្នុងខួរឆ្អឹង (Myelodysplastic Syndrome ឬ Myelofibrosis)<br>49. ការដាក់បញ្ចូលថ្មជំនួយបេះដូង ឬឧបករណ៍ភ្ញោចបេះដូង<br>50. ការវះកាត់ព្យាបាលសរសៃឈាម Coronary<br>51. ការវះកាត់ផ្នែកតូចតាចនៃរាងកាយដើម្បីចូលព្យាបាលផ្នែកខាងក្នុង ឬខាងក្រៅ សរសៃឈាម Aorta នៃប្រអប់ទ្រូង ឬប្រអប់ពោះ<br>52. ការវះកាត់សរសៃអារទែ<br>53. ការព្យាបាលជម្ងឺដាច់សរសៃឈាមខួរក្បាលដោយការវះកាត់សរសៃឈាម Carotid និងការដាក់ stent<br>54. ការរាតត្បាតតិចតួចបំផុត ដោយការឆ្លងកាត់សរសៃឈាមបេះដូងដោយផ្ទាល់(MIDCAB)<br>55. ជំងឺសរសៃឈាមបេះដូងធ្ងន់ធ្ងរ<br>56. ការព្យាបាល Valve បេះដូងដោយមានការជំនួស balloon valvuloplasty<br>57. ការព្យាបាលដោយការជំនួសសន្ទះបិទបើក Percutaneous Valve<br>58. ការវះកាត់ជំងឺរលាកស្រោមបេះដូង Constrictive Pericarditis<br>59. ជំងឺលើសសំពាធឈាមដែលបង្កឡើងដោយជំងឺផ្សេងទៀត<br>60. ការវះកាត់ស្រោមបេះដូង<br>61. ការវះកាត់ដោយការផ្លាស់ប្តូរ Vena-cava Filter | 67. ជំងឺស្លេកស្លាំង (ដែលបណ្តាលមកពីកង្វះគ្រាប់ឈាមក្រហម) អាផ្លាស្ទីក ដែលមិនអាចជាសះស្បើយវិញបាន<br>68. ជំងឺគាំងបេះដូង - នៃកម្រិតធ្ងន់ធ្ងរជាក់លាក់<br>69. ការវះកាត់បង្វៀងផ្លូវសរសៃឈាម Coronary Artery<br>70. ការវះកាត់ប្រអប់ទ្រូង ឬប្រអប់ពោះដើម្បីចូលព្យាបាលផ្នែកខាងក្នុង ឬខាងក្រៅ សរសៃឈាម Aorta នៃប្រអប់ទ្រូង ឬប្រអប់ពោះ<br>71. ជំងឺដាច់សរសៃឈាមខួរក្បាល - ដែលបណ្តាលឲ្យមានការខូចខាតប្រព័ន្ធប្រសាទជាអចិន្ត្រៃយ៍ជាមួយនឹងការបន្តនៃរោគសញ្ញាគ្លីនិក<br>72. ការវះកាត់សន្ទះបេះដូង<br>73. ជំងឺសាច់ដុំបេះដូង<br>74. ជំងឺលើសសំពាធឈាមដោយមិនមានមូលហេតុច្បាស់លាស់<br>75. រោគសញ្ញា Eisenmenger ធ្ងន់ធ្ងរ<br>76. ជំងឺសរសៃឈាមក្បួណារីធ្ងន់ធ្ងរ<br>77. ជំងឺរលាកស្រោមបេះដូងដោយសារការឆ្លងបាក់តេរី |
| **ជំងឺប្រព័ន្ធភាពស៊ាំ (ប្រព័ន្ធរំលាយអាហារ ក្រពះ ពោះវៀន)** | 62. កម្រិតស្រាលនៃ ជំងឺប្រពន្ធ័ភាពស៊ាំប្រឆាំងពេញរាងកាយខ្លួនឯង ដែលបណ្តាលអោយរលាកតម្រងនោម<br>63. ចង្កោមរោគសញ្ញានៃជំងឺរលាកកោសិកាប្រសាទ Guillain-Barre | 78. ជំងឺប្រព័ន្ធភាពស៊ាំ (SLE) ដែលបង្កអោយមានផលវិបាកនៃជំងឺតម្រងនោមធ្ងន់ធ្ងរ<br>79. ជំងឺSclerosis ច្រើនកន្លែង<br>80. ការវិវត្តន៍នៃ Scleroderma<br>81. ជំងឺរលាកសន្លាក់ធ្ងន់ធ្ងរ<br>82. ការឆ្លងវីរុសហ៊ីវតាមរយៈការបញ្ចូលឈាម<br>83. ការឆ្លងវីរុសហ៊ីវតាមរយៈការធ្វើការងារ |
| **ជំងឺតម្រងនោម** | 64. ការវះកាត់យកតម្រងនោមមួយចេញ (ក្នុងចំណោមតម្រងនោមពីរ)<br>65. ជំងឺតម្រង់នោមរ៉ាំរ៉ៃ<br>66. ការកាត់ដុំសាច់នៃក្រពេញអាដ្រេណាល | 84. ការខូចតម្រងនោមដំណាក់កាលចុងក្រោយ |

## តារាងប្រភេទជំងឺធ្ងន់ធ្ងរសម្រាប់អ្នកត្រូវបានធានារ៉ាប់រងអាយុ 30 ថ្ងៃ - 70 ឆ្នាំ

| ប្រភេទជំងឺធ្ងន់ធ្ងរ | ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ |
|---|---|---|
| **ការផ្លាស់ប្តូរសរីរាង្គ** | 85. ការផ្លាស់ប្តូរពោះវៀនតូច (ចាប់ពីមួយម៉ែត្រឡើងទៅ) | 92. ការផ្លាស់ប្តូរបេះដូង<br>93. ការផ្លាស់ប្តូរសួត<br>94. ការផ្លាស់ប្តូរថ្លើម<br>95. ការផ្លាស់ប្តូរតម្រងនោម<br>96. ការផ្លាស់ប្តូរលំពែង<br>97. ការផ្លាស់ប្តូរខួរឆ្អឹង |
| **ជំងឺសរីរាង្គវិញ្ញាណ** (សាច់ដុំ ត្រចៀក ភ្នែក) | 86. ជំងឺពុកឆ្អឹងធ្ងន់ធ្ងរ ដែលបណ្តាលអោយបាក់ឆ្អឹង និងតម្រូវអោយមានការវះកាត់<br>87. ការវះកាត់ដាក់សរីរាង្គខាងក្នុងរបស់ត្រចៀកដែលមានរាងដូចខ្យង<br>88. ជំងឺដក់ពណ៌លើស្រទាប់ទីបីនៃភ្នែក រ៉េទីណា<br>89. ការផ្លាស់ប្តូរកញ្ចក់ភ្នែក<br>90. ជំងឺគ្រុនស្វិតដៃជើង (Poliomyelitis) កម្រិតស្រាល<br>91. ការរលាកធ្ងន់ធ្ងរកម្រិតមធ្យម | 98. ជំងឺគ្រុនស្វិតដៃជើង (Poliomyelitis)<br>99. ជំងឺដំបៅបាក់តេរី<br>100. ការរលាកកម្រិតទីបី |

## តារាងប្រភេទជំងឺធ្ងន់ធ្ងរសម្រាប់អ្នកត្រូវបានធានារ៉ាប់រងអាយុ 30 ថ្ងៃ - 18 ឆ្នាំ

| ប្រភេទជំងឺធ្ងន់ធ្ងរ | ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង | ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ |
|---|---|---|
| **ជំងឺបេះដូង និងប្រព័ន្ធសរសៃឈាម** | 1. ជំងឺកាវ៉ាសាគី (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ)<br>2. ជំងឺជាត់ក្នុងវ័យជំទង់ (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 7. ជំងឺកាវ៉ាសាគីកម្រិតធ្ងន់ធ្ងរ រួមជាមួយផលវិបាកចំពោះបេះដូង<br>8. ជំងឺជាត់ក្នុងវ័យជំទង់ (ដែលតម្រូវឱ្យមានការវះកាត់) |
| **ជំងឺក្រពះពោះវៀន** | 3. ជំងឺទឹកនោមផ្អែម ដែលខូចមុខងារអាំងស៊ុយលីន (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | 9. ជំងឺទឹកនោមផ្អែមសម្រាប់កុមារ ដែលខូចមុខងារអាំងស៊ុយលីនជាអចិន្ត្រៃយ៍ |
| **ជំងឺប្រព័ន្ធភាពស៊ាំ** (ប្រព័ន្ធរំលាយអាហារ ក្រពះពោះវៀន) | 4. ជំងឺរលាកសន្លាក់រ៉ាំរ៉ៃសម្រាប់កុមារ (ផ្អែកលើការធ្វើរោគវិនិច្ឆ័យ) | |
| **ជំងឺតម្រងនោម** | 5. រោគសញ្ញានៃជំងឺតម្រងនោម ដែលតម្រូវឱ្យមានការសម្រាកព្យាបាលនៅមន្ទីរពេទ្យ | 10. ការរលាកសរីរាង្គនៅក្នុងតម្រងនោម ដែលមិនអាចជាសះស្បើយវិញបាន រួមជាមួយរោគសញ្ញានៃជំងឺតម្រងនោម<br>11. រោគសញ្ញានៃជំងឺតម្រងនោមកម្រិតធ្ងន់ធ្ងរ |
| **ជំងឺសួត** | 6. ជំងឺហឺតកម្រិតធ្ងន់ធ្ងរ | 12. ជំងឺហឺតកម្រិតធ្ងន់ធ្ងររ៉ាំរ៉ៃ ដែលមិនអាចជាសះស្បើយឡើងវិញ<br>13. ជំងឺខាន់ស្លាក់ |
| **ជំងឺថ្លើម** | | 14. ជំងឺតំណពូជម៉្យាងហៅថា វីលសុន |
| **ជំងឺសរីរាង្គវិញ្ញាណ** (សាច់ដុំ ត្រចៀក ភ្នែក) | | 15. ជំងឺធ្ងន់ធ្ងរឆ្លងនៅលើដៃ ជើង និងមាត់ដែលមានផលវិបាកគំរាមកំហែងដល់អាយុជីវិត |

# ឧទាហរណ៍



លោក សិលា អាយុ30ឆ្នាំ ជាគណនេយ្យករម្នាក់ដែលមានឪពុកម្តាយនៅក្រោមបន្ទុក។ ដើម្បីធានាថាឪពុកម្តាយរបស់គាត់នឹងមិនមានផលវិបាកផ្នែកហិរញ្ញវត្ថុ ប្រសិនបើមានព្រឹត្តិការណ៍អកុសលណាមួយកើតឡើងចំពោះគាត់ ដូច្នេះគាត់សម្រេចចិត្តទទួលយកការការពារផលិតផលធានារ៉ាប់រងមូលដ្ឋានពី AIA ជាមួយនឹងរយៈពេលនៃការធានារ៉ាប់រង 25 ឆ្នាំ។

ក្នុងនាមជាគណនេយ្យករម្នាក់ គាត់តែងតែប្រុងប្រយ័ត្នក្នុងការរៀបចំផែនការហិរញ្ញវត្ថុរបស់គាត់។ ដោយយល់អំពីការកើនឡើងនៃជំងឺមិនឆ្លង NCDs និងចំណាយលើថ្លៃព្យាបាលខ្ពស់ ដើម្បីការពារហិរញ្ញវត្ថុរបស់គាត់ គាត់សម្រេចចិត្តភ្ជាប់បន្ថែមជាមួយនឹងផលិតផលធានារ៉ាប់រងបន្ថែម AIA 100 **ការពារ** ជាមួយទឹកប្រាក់ធានាចំនួន 20,000 ដុល្លារអាមេរិក។ បុព្វលាភដែលគាត់ត្រូវបង់ក្នុងឆ្នាំដំបូងសម្រាប់ AIA 100 **ការពារ** គឺ US$85.4 ។

| លោក សិលា | ទឹកប្រាក់ធានារ៉ាប់រង (អត្ថប្រយោជន៍លើមរណភាព) | រយៈពេលនៃការធានារ៉ាប់រង | រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង | អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរ |
|---|---|---|---|---|
| 30 ឆ្នាំ | US$100,000 | 25 ឆ្នាំ | 25 ឆ្នាំ | US$20,000 |

ឆ្នាំធានា — 1 — 5 — 15 — កាលកំណត់ចុងក្រោយ







- លោក សិលា ត្រូវបានពិនិត្យរកឃើញថាមានជំងឺមហារីកដែលបានបញ្ជាក់ថាឈានដល់ដំណាក់កាលចុងក្រោយហើយ។ គាត់ទទួលបានប្រាក់សំណងសម្រាប់អត្ថប្រយោជន៍លើជំងឺធ្ងន់ធ្ងរចំនួន US$ 20,000។
- លោក សិលាបានទទួលមរណភាពនៅឆ្នាំធានាទី15 ជាចុងក្រោយក្រុមហ៊ុន អេ អាយ អេ បានផ្តល់សំណងសម្រាប់អត្ថប្រយោជន៍លើមរណភាពជាទឹកប្រាក់ចំនួន US$ 80,000 ។

**អត្ថប្រយោជន៍សរុបផ្តល់សំណងជូន៖ US$ 100,000**

# រយៈពេលនៃការរង់ចាំ

រយៈពេលនៃការរង់ចាំ សំដៅលើរយៈពេលមួយដែលត្រូវបានកំណត់ជាចំនួននៃថ្ងៃ និងរាប់ចាប់ផ្តើមពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង និងក្នុងកំឡុងពេលដែលអាការៈជំងឺធ្ងន់ធ្ងរ មិនត្រូវបានធានាក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ។

ផលិតផលធានារ៉ាប់រងបន្ថែមនេះ តម្រូវឱ្យមានរយៈពេលនៃការរង់ចាំ 120 (មួយរយម្ភៃ) ថ្ងៃនៃថ្ងៃប្រតិទិន សម្រាប់ជំងឺបណ្តាលពីផលវិបាកនៃជំងឺទឹកនោមផ្អែម និងជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង និង 90 (កៅសិប) ថ្ងៃនៃថ្ងៃប្រតិទិន សម្រាប់ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។

ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ធ្វើការស្នើសុំដើម្បីបន្ថែមទឹកប្រាក់ធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម នោះរយៈពេលនៃការរង់ចាំ នឹងអនុវត្តសម្រាប់តែចំនួនដែលកើនឡើង ដោយគិតបន្ទាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង នៃទឹកប្រាក់ធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែមថ្មីត្រូវបានអនុម័ត។

# ទទួលយកសំណើធានារ៉ាប់រង

សូមទាក់ទង ទីប្រឹក្សាផែនការជីវិត AIA ឬសេវាបម្រើអតិថិជន AIA Client Care

ទូរស័ព្ទលេខ : (855) 86 999 242
អ៊ីមែល : KH.Care@aia.com,
គេហទំព័រ : aia.com.kh
តេឡេក្រាម : AIACambodia bot

## ការទាមទារសំណង

ប្រសិនបើអ្នកចង់ធ្វើការទាមទារសំណង អ្នកត្រូវបំពេញទម្រង់បែបបទទាមទារសំណង និងផ្តល់ភស្តុតាង ក្នុងកំឡុងពេល 90 ថ្ងៃធ្វើការ ពីការកើតឡើងនៃព្រឹត្តិការណ៍ដែលត្រូវបានធានារ៉ាប់រង។ ដើម្បីទាមទារសំណង អ្នកត្រូវចូលទៅកាន់ AIA+ ឬ ទាក់ទងមកកាន់ក្រុមការងារផ្នែកអតិថិជន +855 86 999 242 ឬ តេឡេក្រាមរបស់យើងខ្ញុំ AIA Cambodia Bot ឬស្វែងរកជំនួយពីទីប្រឹក្សាផែនការជីវិត អេ អាយ អេ។

រាល់ឯកសារ និងភស្តុតាងចាំបាច់ដែលត្រូវដាក់ភ្ជាប់ជាមួយនឹងទម្រង់បែបបទទាមទារសំណងមកកាន់ក្រុមហ៊ុន AIA មានដូចជា វិក័យប័ត្រច្បាប់ដើម វិញ្ញាបនបត្រវេជ្ជសាស្រ្ត របាយការណ៍ចេញពីមន្ទីរពេទ្យ និងឯកសារវេជ្ជសាស្រ្តផ្សេងទៀត។ ក្នុងករណី កាលបរិច្ឆេទចូលសម្រាក និងកាលបរិច្ឆេទចេញពីមន្ទីរពេទ្យ គឺជាកាលបរិច្ឆេទតែមួយ នៅលើរបាយការណ៍ចេញពីមន្ទីរពេទ្យ ឬវិញ្ញាបនបត្រវេជ្ជសាស្រ្ត ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទ និងពេលវេលាច្បាស់លាស់។ រាល់ឯកសារវេជ្ជសាស្រ្តទាំងអស់ ត្រូវតែចេញដោយ និងទទួលស្គាល់ពីមន្ទីរវេជ្ជសាស្រ្តដែលមានអាជ្ញាបណ្ណស្របច្បាប់លើការផ្តល់សេវាព្យាបាលវេជ្ជសាស្រ្តនៅក្នុងប្រទេស។

អ្នកទាមទារសំណងអាចស្នើសុំសំណង ប្រសិនបើករណីត្រូវទាមទារសំណង និងការព្យាបាលផ្នែកវេជ្ជសាស្រ្តកើតឡើងក្នុងកំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

## ករណីមិនធានា

**AIA 100 ការពារ** មិនធានាលើ៖

1. ជំងឺ ឬការវះកាត់ណាមួយដែលមិនមែនជាជំងឺធ្ងន់ធ្ងរដូចបានកំណត់ក្នុងតារាងជំងឺធ្ងន់ធ្ងរ ឬ
2. រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរ ដែលបានកំណត់ថាជា "ជំងឺបណ្តាលពីផលវិបាកនៃជំងឺទឹកនោមផ្អែម" ឬ "ជំងឺធ្ងន់ធ្ងរដំណាក់កាលដំបូង" និង "ជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ" ត្រូវបានបង្ហាញឲ្យឃើញមុន ឬក្នុងកំឡុងរយៈពេលនៃការរង់ចាំ ឬ
3. អាការៈជំងឺធ្ងន់ធ្ងរកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ពីស្ថានភាពមុនពេលធានារ៉ាប់រងដូចបានកំណត់ ដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ
4. អាការៈជំងឺធ្ងន់ធ្ងរ ដែលតាមគំនិតរបស់ក្រុមហ៊ុន កើតមានដោយផ្ទាល់ ឬដោយប្រយោល ពីវត្តមាននៃមេរោគ អេដស៍ (AIDS ឬ HIV) និងលក្ខខណ្ឌផ្សេងៗដែលពាក់ព័ន្ធ លើកលែងតែ ការឆ្លងវីរុសហ៊ីវតាមរយៈការបញ្ចូលឈាម និង ការឆ្លងវីរុសហ៊ីវតាមរយៈការធ្វើការងារ ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ I - តារាងជំងឺធ្ងន់ធ្ងរ។ ក្រុមហ៊ុន សូមរក្សាសិទ្ធិ ក្នុងការតម្រូវឱ្យអ្នកត្រូវបានធានារ៉ាប់រងទៅពិនិត្យឈាមរកវីរុសហ៊ីវ ដែលជាលក្ខខណ្ឌដំបូងបង្អស់ក្នុងការទទួលយកការទាមទារសំណងណាមួយ។ សម្រាប់គោលបំណងនៃផលិតផលធានារ៉ាប់រងបន្ថែមនេះ៖
    i. និយមន័យនៃជំងឺអេដស៍ (AIDS) ត្រូវតែជានិយមន័យដែលត្រូវបានប្រើ ដោយអង្គការសុខភាពពិភពលោកក្នុងឆ្នាំ 1987 ឬការកែប្រែណាមួយក្រោយមកទៀត ទៅលើនិយមន័យនោះដោយអង្គការសុខភាពពិភពលោក។
    ii. ការឆ្លងមេរោគនេះ ត្រូវចាត់ទុកថាបានកើតឡើងនៅពេលដែលការពិនិត្យឈាម ឬការពិនិត្យផ្សេងៗដែលពាក់ព័ន្ធ ហើយដែលតាមយោបល់របស់ក្រុមហ៊ុន បង្ហាញថាមានផ្ទុកវីរុសហ៊ីវ ឬអង់ទីករប្រឆាំងមេរោគនេះ ឬ
5. រាល់ការធ្វើរោគវិនិច្ឆ័យលើអាការៈជំងឺធ្ងន់ធ្ងរណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពីជំងឺ ឬពិការភាពពីកំណើត ឬដោយមេរោគពីកំណើត ដែលត្រូវបានពិនិត្យ ឬធ្វើរោគវិនិច្ឆ័យឃើញ មុនពេលអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ លើកលែងតែអាការៈជំងឺដែលបានចែងក្នុងបណ្ណសន្យារ៉ាប់រងនេះ ឬ
6. អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលកើតឡើងដោយសារការធ្វើឲ្យរបួសខ្លួនឯង ឬ
7. អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលកើតឡើងដោយផ្ទាល់ពីការពិសាគ្រឿងស្រវឹង ឬប្រើប្រាស់ថ្នាំញៀនហួសកម្រិត ឬ
8. អាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលបណ្តាលមកពីស្ថានភាពផ្លូវកាយ ឬផ្លូវចិត្ត ដែលបានកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាននៃផលិតផលធានារ៉ាប់រងបន្ថែមនេះ (ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ) ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំធានារ៉ាប់រង ឬរបាយការណ៍សុខភាព ឬ
9. ព្រឹត្តិការណ៍ណាមួយដែលបង្កឱ្យមានការទាមទារសំណង ទៅលើអ្នកត្រូវបានធានារ៉ាប់រង ដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនារបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គលណាម្នាក់ដែលនឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដែលត្រូវបង់ជូន ឬ
10. ការបរិច្ចាគផ្នែកណាមួយនៃរាងកាយរបស់អ្នកដែលត្រូវបានធានារ៉ាប់រង ឬ
11. ចូលរួមក្នុងការបើកបរ ឬជិះ ក្នុងប្រភេទកីឡាប្រណាំងណាមួយ សកម្មភាពក្រោមទឹក ឬសកម្មភាពដែលមានគ្រោះថ្នាក់ផ្សេងទៀត ដូចជាការឡើងភ្នំ ឬចូលរូងភ្នំ ឬការលោតឆ័ត្រយោង ឬការលោតបាងហ្គី ឬ
12. ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស។

**ការិយាល័យកណ្តាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដីហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA